| បញ្ជាសម្រាប់ការបញ្ជូនទៅទទួលការព្យាបាល សំរាប់វិបល្លាសដោយការ ប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុ G.L. c. 123, § 35 | លេខសំណុំរឿង<br>អង្គនាព | តុលាការវិនិច្ឆ័យនៃរដ្ឋម៉ាស្សាជូសេត្ស៍ |
|---|---|---|

| ឈ្មោះអ្នកឆ្លើយតប: | ថ្ងៃខែឆ្នាំកំណើត: | អាយុ: | លេខសួស្សាល់: | ភេទ: |
|---|---|---|---|---|
| | | | | |

មន្ទីរថែរក្សាដែលបុគ្គលត្រូវបានគេបញ្ជូនទៅព្យាបាល:

## បញ្ជារដ្ឋប្បវេណីឱ្យទៅទទួលការព្យាបាល យោងតាមច្បាប់ទូទៅរបស់រដ្ឋ G.L. c. 123, § 35

បន្ទាប់ពីការពិនិត្យលើអ្នកឆ្លើយតបដែលមានឈ្មោះដូចខាងលើដោយគ្រូពេទ្យដែលមានសមត្ថភាព អ្នកចិត្តសាស្ត្រ ឬបុគ្គលិកសង្គម ការតែងតាំងមេធាវីម្នាក់ បើសិនជាចាំបាច់ និងសវនាការដែលត្រូវបានគេធ្វើឡើង ស្របតាមច្បាប់របស់តុលាការ **តុលាការ**នេះបានកំណត់ថា មានភស្តុតាងច្បាស់លាស់ និងគួរឱ្យទុកចិត្ត ថាអ្នកឆ្លើយតបជាបុគ្គលម្នាក់ដែលមានបញ្ហាវិបល្លាសធ្ងន់ធ្ងរ (វិបល្លាសដោយការប្រើគ្រឿងញៀណ) (វិបល្លាសដោយការប្រើគ្រឿងស្រវឹង) (ឬទាំងពីរ) ដូចលក្ខខណ្ឌដែលត្រូវបានគេឱ្យនិយមន័យក្នុងច្បាប់ទូទៅជំពូក 123, § 35, **ហើយ**ថា ការខកខានមិនបានបញ្ជូនអ្នកឆ្លើយតបទៅទទួលការព្យាបាលនឹង**បង្កើតនូវហានិភ័យធ្ងន់ធ្ងរ** ដូចដែលបានចែងនៅក្នុងច្បាប់ទូទៅជំពូក 123, §1 ដល់អ្នកឆ្លើយតបផ្ទាល់ ឬដល់អ្នកដទៃ **ហើយ**ថា មានតែមធ្យោបាយសមរម្យមួយគត់សម្រាប់អ្នកឆ្លើយតប គឺត្រូវទៅទទួលការព្យាបាលនៅក្នុងកន្លែងមួយមានសុវត្ថិភាព។

**ដូច្នេះ** យោងតាមច្បាប់ទូទៅជំពូក 123, § 35, **តុលាការនេះចេញបញ្ជា**ថា អ្នកឆ្លើយតបដែលនឹងត្រូវគេបញ្ជូនទៅ**ទទួលការព្យាបាល** នៅមន្ទីរដែលត្រូវបានគេបញ្ជាក់ខាងលើ សម្រាប់មូលហេតុនៃការថែទាំ និងការព្យាបាលអ្នកជំងឺក្នុងមន្ទីរព្យាបាលសម្រាប់កំឡុងពេលមួយរយៈ មិនឱ្យលើសពី 90ថ្ងៃ ហើយថា អគ្គនាយកនៃកន្លែងទទួល និងអគ្គនាយកនៃកន្លែងណាក៏ដោយដែលអ្នកឆ្លើយតបត្រូវបានគេបញ្ជូន ប្រគល់ និងទទួលនាទីជាអាណាព្យាបាលលើភាគីឆ្លើយតបរហូតដល់ការបញ្ជូនទៅព្យាបាលនេះត្រូវគេបញ្ចប់ត្រឹមត្រូវ។

## បញ្ជាបន្ថែម

**I. ដឹកជញ្ជូនទៅមន្ទីរ:** តុលាការបង្គាប់ឱ្យមន្ត្រីណាដែល**មានសមត្ថកិច្ច**បញ្ជូនអ្នកឆ្លើយតបប្រគល់ឱ្យអគ្គនាយកនៃមន្ទីរព្យាបាលបែបនេះ និងផ្តល់ព័ត៌មានបញ្ជាក់ត្រឡប់ជូនដល់ក្រឡាបញ្ជីនៃតុលាការនេះក្នុងចន្លោះដែលបានផ្តល់ឱ្យខាងក្រោម។ គ្មានអ្វីនៅក្នុងបទបញ្ជានេះ ហាមមិនឱ្យនគរបាលចាត់វិធានការណាមួយដែលចាត់ទុកថាជាការចាំបាច់ទាក់ទងនឹងសុខភាពរបស់អ្នកឆ្លើយតបមុនពេលការប្រគល់ជូនអ្នកឆ្លើយតបទៅមន្ទីរព្យាបាលនោះឡើយ ដរាបណានគរបាលនោះនៅមានអាណាព្យាបាលលើអ្នកឆ្លើយតប រហូតដល់ការបញ្ជូនខ្លួននោះត្រូវបានបញ្ចប់សព្វគ្រប់។

**II. ការរត់គេច, បញ្ជូន, ដោះលែងពីអាណាព្យាបាល:** អគ្គនាយកនៃមន្ទីរណាមួយក៏ដោយដែលមានអាណាព្យាបាលលើអ្នកឆ្លើយតបត្រូវបាន**បង្គាប់ឱ្យជូនដំណឹង**ដល់ការិយាល័យក្រឡាបញ្ជីតាមរយៈការបញ្ជូនសណ្ឋានព័ត៌មាន "**ដំណឹងពីការរត់គេច បញ្ជូន ឬដោះលែង**" ដែលតម្រូវដោយតុលាការទៅតុលាការដែលបានចេញបញ្ជានេះ។ សេចក្តីជូនដំណឹងត្រូវគេបញ្ជូនទៅតុលាការដូចមានចែងនៅក្នុងបញ្ជីបញ្ជូនអេឡិចត្រូនិចរបស់តុលាការដែលត្រូវបានផ្តល់ទៅមន្ទីររបស់អ្នក។ សេចក្តីជូនដំណឹងនេះនឹងត្រូវគេបញ្ជូនក្នុងរយៈពេល 24 ម៉ោងនៃការ**រត់គេច**របស់អ្នកឆ្លើយតបពីអាណាព្យាបាល **ការបញ្ជូន**ទៅកន្លែងផ្សេងទៀត ឬ**ការដោះលែង**ពីមន្ទីរអាណាព្យាបាល។

**III. វិធានការទាក់ទងនឹងអាវុធ** បទបញ្ជាពីការឱ្យទៅទទួលការព្យាបាលនេះហាមមិនឱ្យគេចេញប័ណ្ណសម្គាល់អត្តសញ្ញាណកាំភ្លើង ឬអាជ្ញាប័ណ្ណដល់អ្នកឆ្លើយតបដើម្បីកាន់អាវុធឡើយ លុះត្រាតែមានការស្នើសុំឱ្យមានការយល់យោគដែលក្រោយមកត្រូវបានគេអនុញ្ញាត។

**បទបញ្ជាពីការឱ្យទៅទទួលការព្យាបាលនេះនឹងផុតកំណត់នៅ__________________លុះត្រាតែត្រូវបានបញ្ចប់ជាលាយលក្ខណ៍អក្សរពីអគ្គនាយកដោយអនុលោមតាមច្បាប់ G.L. c.123, §35។**

| ថ្ងៃចេញបញ្ជា: | ហត្ថលេខារបស់ចៅក្រម: |
|---|---|
| | |

## ការត្រឡប់មកវិញរបស់មន្ត្រីនៃសេវាកម្ម

ខ្ញុំបានបញ្ជូនអ្នកឆ្លើយតបទៅកន្លែងព្យាបាលដែលមានឈ្មោះខាងលើជាមួយនឹងច្បាប់ចម្លងនៃបញ្ជានេះ

| ថ្ងៃដែលបានបញ្ជូនទៅដល់: | ហត្ថលេខារបស់មន្ត្រី: | ងារបស់មន្ត្រី: |
|---|---|---|
| | | |

This form is for reference only. Do not submit to the court.